# របាយការណ៍
# ស្តីពីសមិទ្ធផលការងារសម្រេចបានសំខាន់ៗរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៥ ឆ្នាំ២០២២-២០២៥

**ថ្ងៃចន្ទ ១០រោច ខែស្រាពណ៍ ឆ្នាំមមី អដ្ឋស័ក ព.ស.២៥៧០**

**រាជធានីភ្នំពេញ ថ្ងៃទី៧ ខែកញ្ញា ឆ្នាំ២០២៦**

# មាតិកា

I. សារតារនៃកំណែទម្រង់និងបរិបទអាណត្តិទី៥

II. សមាសភាព រចនាសម្ព័ន្ធ និងធនធានមនុស្ស

III. សមិទ្ធផលការងារសំខាន់ៗ អាណត្តិទី៥(២០២២-២០២៥)

IV. ការវាយតម្លៃរួម និងបញ្ហាប្រឈម

V. ទិសដៅយុទ្ធសាស្ត្រ សម្រាប់អាណត្តិទី៦

VI. សេចក្តីសន្និដ្ឋានរួម

# I-សាវតារនៃកំណែទម្រង់និងបរិបទអាណត្តិទី៥

## ១-សាវតារនៃកំណែទម្រង់វិមជ្ឈការនិងវិសហមជ្ឈការ

ឆ្នាំ២០០១ → ឆ្នាំ២០០២ → ឆ្នាំ២០០៨

ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ



រដ្ឋបាលឯកភាព

ព្រឹត្តិការណ៍បើកទំព័រថ្មីក្នុងការផ្លាស់ប្តូររដ្ឋបាលឃុំ សង្កាត់

-ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
-ច្បាប់ស្តីពីការជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់

កម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ដំណាក់កាលទី១ (២០១០-២០២០)


រាជរដ្ឋាភិបាលកម្ពុជា
គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ

កម្មវិធីជាតិ
សម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ
នៅថ្នាក់ក្រោមជាតិ
ដំណាក់កាលទី២ (២០២១-២០៣០)

បានទទួលការអនុម័តពីរាជរដ្ឋាភិបាលកម្ពុជា
នាថ្ងៃព្រហស្បតិ៍ ៥កើត ខែមិគសិរ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
ត្រូវនឹងថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០២១

# I-សាវតារនៃកំណែទម្រង់និងបរិបទអាណត្តិទី៥

## ២-ការវិវត្តតាមអាណត្តិនៃក្រុមប្រឹក្សាឃុំ សង្កាត់ (២០០២-២០២៥)

អាណត្តិទី១៖ សមាជិក ១១.២៦១រូប
(០៣ កុម្ភៈ ២០០២)

អាណត្តិទី២៖សមាជិក ១១.៣៥៣រូប
(០១ មេសា ២០០៧)

អាណត្តិទី៣៖សមាជិក ១១.៤៥៩រូប
(០៣ មិថុនា ២០១២)

អាណត្តិទី៤៖សមាជិក ១១.៥៧២រូប
(០៤ មិថុនា ២០១៧)

អាណត្តិទី៥៖សមាជិក ១១.៦២២រូប
(០៥ មិថុនា ២០២២)

អាណត្តិទី៦៖
(០៦ មិថុនា ២០២៧)

# I-សាវតារនៃកំណែទម្រង់និងបរិបទអាណត្តិទី៥

## ៣-បរិបទអាណត្តិទី៥ និងសារៈសំខាន់នៃការរៀបចំសន្និបាត

**សន្និបាតទី១**
- ១៥-១៧ សីហា ២០០៦ (២០០២-២០០៧)

**សន្និបាតទី១**
- ១៧-១៨ សីហា ២០១១ (២០០៧-២០១២)

**សន្និបាតទី៣**
- ៧-៨ កញ្ញា ២០២៦ (២០២២-២០២៥)

**តម្លៃជាប្រវត្តិសាស្ត្រក្នុងការ៖**

១- ឆ្លុះបញ្ចាំង និងវាយតម្លៃលើដំណើរការអនុវត្តតួនាទីភារកិច្ច និងសមិទ្ធផលការងាររបស់ក្រុមប្រឹក្សាឃុំសង្កាត់។

២- កំណត់ឱ្យបានច្បាស់លាស់នូវផលជះនៃការអនុវត្តគោលនយោបាយ ស្ថានភាពសមត្ថភាពធនធានមនុស្ស និងបញ្ហាប្រឈមនិងហានិភ័យគន្លឹះនានា។

៣- ដកស្រង់ឧត្តមានុវត្តន៍ និងមេរៀនពិសោធន៍ ដើម្បីបម្លែងជាធាតុចូលយុទ្ធសាស្ត្រ ក្នុងការកំណត់ទិសដៅ វិធានការ និងអនុសាសន៍គន្លឹះៗ សំដៅគាំទ្រដល់ក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៦។

# II-សមាសភាព រចនាសម្ព័ន្ធ និងធនធានមនុស្ស

## ១-សមាសភាព និងភាពជាតំណាងរបស់ក្រុមប្រឹក្សាឃុំ សង្កាត់

ចំនួនសមាជិក
ក្រុមប្រឹក្សាឃុំ
សង្កាត់សរុប
១១.៦២២រូប
ស្រី២.៥៦៩រូប
ស្មើ២២,៣%



# II-សមាសភាព រចនាសម្ព័ន្ធ និងធនធានមនុស្ស

## ២-ស្មៀនឃុំ សង្កាត់ និងបុគ្គលិកគាំទ្រ



# II-សមាសភាព រចនាសម្ព័ន្ធ និងធនធានមនុស្ស

## ៣-ការគ្រប់គ្រងភូមិ និងរចនាសម្ព័ន្ធមន្ត្រីភូមិ

ចំនួនភូមិនៅទូទាំងប្រទេស សរុបចំនួន
១៤.៥៩០

អនុក្រឹត្យលេខ២៨០ អនក្រ.បក ចុះថ្ងៃទី៤ ខែធ្នូ ឆ្នាំ២០២៤ ស្តីពីគោលការណ៍ និងបទប្បញ្ញត្តិនៃការកំណត់លេខកូដសម្គាល់ រាជធានី ខេត្តក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ និងភូមិ នៃព្រះរាជាណាចក្រកម្ពុជា

**មេភូមិ**

**អនុប្រធានភូមិ**

**សមាជិកភូមិ**

សមាសភាពមន្ត្រីភូមិនៅទូទាំងប្រទេស មានសរុបចំនួន ៤៣.៧៧០រូប ស្ត្រីចំនួន ១២.៥២៨រូប (ស្មើនឹង ២៩% នៃចំនួនសរុប)

# III-សមិទ្ធផលការងារសំខាន់ៗ អាណត្តិទី៥(២០២២-២០២៥)

## ១-ការពង្រឹងក្របខ័ណ្ឌគតិយុត្ត អំណាចបញ្ញត្តិ និងរបៀបរបបការងារ

- ការបន្តពង្រឹងក្របខ័ណ្ឌគតិយុត្តៈ

  គ.ជ.អ.ប. ដោយមានលេខាធិការដ្ឋាន គ.ជ.អ.ប ជាសេនាធិការ និងមានការចូលរួមយ៉ាងសកម្មពីអគ្គនាយកដ្ឋានរដ្ឋបាល ក្រសួងមហាផ្ទៃ បានសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ រៀបចំ និងដាក់ឱ្យអនុវត្តនូវច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងរដ្ឋបាលឃុំ សង្កាត់ ចំនួន៥៤ (បន្ថែមលើលិខិតបទដ្ឋានប្រមាណជិត ៦០០ ដែលបានដាក់ចេញតាំងពីឆ្នាំ២០០២)។

- ច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ឆ្នាំ២០២៣
- អនុក្រឹត្យលេខ ១៥៣ អនក្រ.បក ស្តីពីការផ្ទេរធនធានពីថវិការដ្ឋជូនមូលនិធិឃុំ សង្កាត់
- អនុក្រឹត្យលេខ ១៥៤ អនក្រ.បក ស្តីពីការផ្ទេរធនធានបន្ថែមសម្រាប់ចំណាយអភិវឌ្ឍន៍មូលដ្ឋាន,
- អនុក្រឹត្យលេខ ២៤៩ អនក្រ.បក ស្តីពីការកំណត់អត្រាចែករំលែកពីសេវាសាធារណៈ និងទ្រព្យសម្បត្តិរដ្ឋ,
- អនុក្រឹត្យលេខ ២៨០ អនក្រ.បក ស្តីពីការកំណត់លេខកូដសម្គាល់រដ្ឋបាល,
- ប្រកាសលេខ ១៨០ ស្តីពីសៀវភៅណែនាំប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុឃុំ សង្កាត់ និង
- សារាចរអន្តរក្រសួងលេខ ០០៧ (២០២៥) ស្តីពីការគ្រប់គ្រងថវិកាសេវាសង្គម និងអនាម័យបរិស្ថាន។

# III-សមិទ្ធផលការងារសំខាន់ៗ អាណត្តិទី៥(២០២២-២០២៥)

## ១-ការពង្រឹងក្របខ័ណ្ឌគតិយុត្ត អំណាចបញ្ញត្តិ និងរបៀបរបបការងារ

❑ ការប្រើប្រាស់អំណាចបញ្ញត្តិ និងកិច្ចការរដ្ឋបាល៖




❑ របៀបរបបប្រជុំរបស់ក្រុមប្រឹក្សា៖



# III-សមិទ្ធផលការងារសំខាន់ៗ អាណត្តិទី៥(២០២២-២០២៥)

## ២-ការគ្រប់គ្រងហិរញ្ញវត្ថុ ផែនការអភិវឌ្ឍន៍ និងការវិនិយោគមូលដ្ឋាន

- ការកើនឡើងនៃធនធានហិរញ្ញវត្ថុ និងរចនាសម្ព័ន្ធមូលនិធិថ្មី (គិតជាលានដុល្លារ)៖



# III-សមិទ្ធផលការងារសំខាន់ៗ អាណត្តិទី៥(២០២២-២០២៥)

## ២-ការគ្រប់គ្រងហិរញ្ញវត្ថុ ផែនការអភិវឌ្ឍន៍ និងការវិនិយោគមូលដ្ឋាន

- ការរៀបចំផែនការ និងកម្មវិធីវិនិយោគបីឆ្នាំរំកិល៖ រដ្ឋបាលឃុំ សង្កាត់ បានរៀបចំ និងអនុវត្ត ផែនការអភិវឌ្ឍន៍រយៈពេលប្រាំឆ្នាំ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលជាប្រចាំ ដោយឈរលើការពិគ្រោះយោបល់ និងការចូលរួមពីប្រជាពលរដ្ឋ ព្រមទាំងបានចូលរួមក្នុងសិក្ខាសាលា សមាហរណកម្មផែនការនៅថ្នាក់ក្រុង ស្រុក ខណ្ឌដើម្បីកៀរគរធនធានបន្ថែម។

# III-សមិទ្ធផលការងារសំខាន់ៗ អាណត្តិទី៥(២០២២-២០២៥)

## ២-ការគ្រប់គ្រងហិរញ្ញវត្ថុ ផែនការអភិវឌ្ឍន៍ និងការវិនិយោគមូលដ្ឋាន

❑ សមិទ្ធផលគម្រោងវិនិយោគដែលបានអនុវត្តបញ្ចប់(២០២២-២០២៥)

ផ្នែកសេដ្ឋកិច្ច និងហេដ្ឋារចនាសម្ព័ន្ធ(៩.៨២៤គម្រោង)៖

- ❑ បានសាងសង់និងកែលម្អផ្លូវបេតុងប្រវែង ៤.៥២០,៨២គ.ម
- ❑ ផ្លូវកៅស៊ូប្រវែង ៤០,២៣គ.ម
- ❑ ផ្លូវគ្រួសក្រហមប្រវែង ១១.៤៣៤,១៨ គ.ម
- ❑ ស្ពានបេតុងខ្នាតតូចប្រវែង ២៩,១០គ.ម

ផ្នែកសង្គមកិច្ច(៣៤.៦៣០គម្រោង/ សកម្មភាព)៖

- ❑ មត្តេយ្យសិក្សាសហគមន៍
- ❑ សុខភាពមាតានិងកុមារ
- ❑ អាហារូបត្ថម្ភ
- ❑ សុខភាពបន្តពូជ
- ❑ ទឹកស្អាត អនាម័យ និង
- ❑ កិច្ចការពារជនងាយរងគ្រោះ។

# III-សមិទ្ធផលការងារសំខាន់ៗ អាណត្តិទី៥(២០២២-២០២៥)

## ២-ការគ្រប់គ្រងហិរញ្ញវត្ថុ ផែនការអភិវឌ្ឍន៍ និងការវិនិយោគមូលដ្ឋាន

❑ សមិទ្ធផលគម្រោងវិនិយោគដែលបានអនុវត្តបញ្ចប់(២០២២-២០២៥)

ផ្នែកធនធានធម្មជាតិ និងបរិស្ថាន (៧.៥៨៥គម្រោង/សកម្មភាព)៖

- ❑ ការគ្រប់គ្រងសំរាម/ សំណល់
- ❑ ការដាំដើមឈើ
- ❑ អភិរក្សព្រៃសហគមន៍ និង
- ❑ ការបន្សាំនឹងការប្រែប្រួលអាកាសធាតុ។

ផ្នែករដ្ឋបាល សន្តិសុខ និងសណ្តាប់ធ្នាប់(១២.៥២២គម្រោង/ សកម្មភាព)៖

- ❑ ការផ្សព្វផ្សាយគោលនយោបាយភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព
- ❑ ការល្បាត និង
- ❑ ការទប់ស្កាត់បទល្មើសមូលដ្ឋាន។

# III-សមិទ្ធផលការងារសំខាន់ៗ អាណត្តិទី៥(២០២២-២០២៥)

## ៣-ការផ្តល់សេវារដ្ឋបាល សេវាសាធារណៈ និងកិច្ចគាំពារសង្គម

- ការផ្តល់សេវារដ្ឋបាលតាមយន្តការច្រកចេញចូលតែមួយ៖ សេវាអត្រានុកូលដ្ឋាន សរុបចំនួន ៨.៥៨៧.១៥៦សេវា (ជាមធ្យម ១.២៩៩ សេវា/ឃុំ-សង្កាត់/ឆ្នាំ) និងសេវាអត្តសញ្ញាណកម្ម សរុបចំនួន ៥.១៨២.០៤២សេវា
- លិខិតបញ្ជាក់រដ្ឋបាលផ្សេងៗ៖ សរុបចំនួន ៩.០៥០.៨៧២សេវា (ជាមធ្យម ១.៣៧០ សេវា/ឃុំ-សង្កាត់/ឆ្នាំ)
- ការគ្រប់គ្រងមត្តេយ្យសិក្សាសហគមន៍៖ សរុបចំនួន ៣.៣៤៨កន្លែង ក្នុងឃុំ សង្កាត់ចំនួន ១.១១៩ (សម្រាប់ឆ្នាំសិក្សា២០២៤-២០២៥) និងមានគ្រូបង្រៀនកិច្ចសន្យាចំនួន ៣.៣៤៨នាក់
- ការអនុវត្តកម្មវិធីជាតិគាំពារសង្គម៖ រដ្ឋបាលឃុំ សង្កាត់ និងមន្ត្រីភូមិ បានបំពេញតួនាទីស្នូលក្នុងការកំណត់អត្តសញ្ញាណគ្រួសារក្រីក្រ និងក្រុមជនងាយរងហានិភ័យ ការផ្ទៀងផ្ទាត់ទិន្នន័យ ការចុះផ្សព្វផ្សាយដល់ខ្នងផ្ទះ និងការសម្របសម្រួលឱ្យប្រជាពលរដ្ឋទទួលបានបណ្តូសមធម៌ និងអត្ថប្រយោជន៍ពីកម្មវិធីឧបត្ថម្ភសាច់ប្រាក់របស់រាជរដ្ឋាភិបាលប្រកបដោយសមធម៌ និងបរិយាបន្ន។

# III-សមិទ្ធផលការងារសំខាន់ៗ អាណត្តិទី៥(២០២២-២០២៥)

## ៤-ការសម្រុះសម្រួលដោះស្រាយវិវាទ និងសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ

- ❑ រដ្ឋបាលឃុំ សង្កាត់ ទទួលបានសំណើសុំសម្រុះសម្រួលសរុបចំនួន ២៣០.៤៨១ករណី (មធ្យម៣៥ ករណី/ឃុំ-សង្កាត់/ឆ្នាំ) ក្នុងនោះបានសម្រុះសម្រួលបញ្ចប់នៅថ្នាក់ឃុំ សង្កាត់បានចំនួន២១៥.៧១៣ករណី(ស្មើនឹង៩៣%) និងបញ្ជូនបន្តទៅស្ថាប័ន មានសមត្ថកិច្ចចំនួន ១៤.៧៦៨ករណី (ស្មើនឹង ៧%)
- ❑ ការអនុវត្តគោលនយោបាយ«ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព»៖ បានសហការជិតស្និទ្ធជាមួយប៉ុស្តិ៍នគរបាលរដ្ឋបាល និងកម្លាំងប្រជាការពារ ក្នុងការល្បាត ទប់ស្កាត់បទល្មើស គ្រឿងញៀន ក្មេងទំនើង និងអំពើហិង្សាក្នុងគ្រួសារ។ តាមរយៈការប្រឡងប្រណាំងប្រចាំឆ្នាំរបស់ក្រសួងមហាផ្ទៃ មានឃុំ សង្កាត់ចំនួន ១.២៤៣ ទទួលបានចំណាត់ថ្នាក់លេខ១, ចំនួន ៣៦៤ ទទួលបានលេខ២ និងចំនួន ៤១ ទទួលបានលេខ៣។
- ❑ ការគាំទ្រការងារបោះឆ្នោត៖ គិតត្រឹមឆ្នាំ២០២៥ មានប្រជាពលរដ្ឋមានឈ្មោះក្នុងបញ្ជីបោះឆ្នោតសរុបចំនួន ១០.១៦២.២៣២នាក់។

## III-សមិទ្ធផលការងារសំខាន់ៗ អាណត្តិទី៥(២០២២-២០២៥)

### ៥-អភិបាលកិច្ច បរិវត្តកម្មឌីជីថល និងការកសាងសមត្ថភាព

- ការងារគណនេយ្យភាពសង្គម (ISAF)៖ បានពង្រីកវិសាលភាពទូទាំងប្រទេស រួមមាន៖ រដ្ឋបាលឃុំ សង្កាត់ចំនួន ១.៥៥០ (ស្មើនឹង ៩៤%), សាលាបឋមសិក្សាចំនួន ៦.៩២២ (ស្មើនឹង ៩៤%) និងមណ្ឌលសុខភាពចំនួន ១.២៥៦ (ស្មើនឹង ៩៦%) នៅក្នុងក្រុង ស្រុក ខណ្ឌចំនួន ១៩០ នៃរាជធានី-ខេត្តទាំង ២៥ ដែលបានលើកកម្ពស់តម្លាភាព និងការចូលរួមត្រួតពិនិត្យពីប្រជាពលរដ្ឋ
- ការធ្វើបរិវត្តកម្មឌីជីថល៖ បានដាក់ឱ្យដំណើរការប្រព័ន្ធបច្ចេកវិទ្យាសំខាន់ៗ រួមមាន ប្រព័ន្ធ FMIS Portal សម្រាប់ស្នើ និងបញ្ជូនឯកសារចំណាយ, ប្រព័ន្ធតាមដានថវិការដ្ឋបាលឃុំ សង្កាត់ និងកម្មវិធីឌីជីថលគណនេយ្យភាពសង្គម ដែលជួយកាត់បន្ថយការប្រើក្រដាស បង្កើនល្បឿន និងពង្រឹងភាពត្រឹមត្រូវនៃទិន្នន័យ។
- ការកសាងសមត្ថភាព និងភាពជាដៃគូ៖ សមាជិកក្រុមប្រឹក្សា ស្មៀន និងបុគ្គលិក បានចូលរួមវគ្គបណ្តុះបណ្តាលនានា សរុបចំនួន ១៤៤.៣៣៧ វគ្គ/លើក ព្រមទាំងបានសហការយ៉ាងជិតស្និទ្ធជាមួយសម្ព័ន្ធភាពជាតិក្រុមប្រឹក្សាថ្នាក់មូលដ្ឋាន អង្គការសង្គមស៊ីវិល និងដៃគូអភិវឌ្ឍន៍ ក្នុងការលើកកម្ពស់សមត្ថភាព និងភាពជាអ្នកដឹកនាំរបស់ស្ត្រីនៅមូលដ្ឋាន។

# IV-ការវាយតម្លៃរួម និងបញ្ហាប្រឈម

## ១-ការវាយតម្លៃរួមលើផលជះជាវិជ្ជមាន

ក្រុមប្រឹក្សាឃុំ សង្កាត់បានបន្តវិវត្ត យ៉ាងពិតប្រាកដ ពីអង្គភាពដែលផ្តោតជាចម្បងលើការងាររដ្ឋបាល លិខិតស្នាម និងការសាងសង់ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ទៅជារដ្ឋបាលមូលដ្ឋានពហុវិស័យ ដែលបំពេញតួនាទីស្នូលលើការផ្តល់សេវាសាធារណៈ សេវាសង្គម កិច្ចគាំពារសង្គម បរិស្ថាន គណនេយ្យភាព សន្តិសុខ និងការធ្វើបរិវត្តកម្មឌីជីថល។

- ❖ ពង្រឹងលទ្ធិប្រជាធិបតេយ្យ និងអភិបាលកិច្ចមូលដ្ឋាន
- ❖ លើកកម្ពស់ការតភ្ជាប់ និងសេដ្ឋកិច្ចមូលដ្ឋាន
- ❖ ការនាំសេវារដ្ឋឱ្យកាន់តែកៀកប្រជាពលរដ្ឋ
- ❖ បង្កើនការវិនិយោគលើមូលធនមនុស្ស និងសុខុមាលភាព
- ❖ ពង្រឹងការគាំពារក្រុមងាយរងគ្រោះ
- ❖ រក្សាសន្តិសុខ និងសាមគ្គីភាពសហគមន៍
- ❖ លើកកម្ពស់តម្លាភាព និងទំនើបកម្មរដ្ឋបាល។

ការវាយតម្លៃបង្ហាញនូវចំណុចខ្វះខាតផ្នែកសូចនាករវាស់វែង ដោយការកត់ត្រានិងរាយការណ៍ផ្តោតខ្លាំងលើ «ទិន្នផល/បរិមាណដែលបានធ្វើ» (Output) ដូចជា ចំនួនគម្រោង ប្រវែងផ្លូវ ឬចំនួនសេវា ខណៈទិន្នន័យអំពី «ផលសម្រេចនិងការផ្លាស់ប្តូរជីវភាពជាក់ស្តែងរបស់ប្រជាពលរដ្ឋ»

# IV-ការវាយតម្លៃរួម និងបញ្ហាប្រឈម

## ២-បញ្ហាប្រឈមគន្លឹះ

ក្រុមប្រឹក្សា និងរដ្ឋបាលឃុំ សង្កាត់ ក្នុងអាណត្តិទី៥ នៅតែជួបប្រទះនូវបញ្ហាប្រឈម និងឧបសគ្គមួយចំនួន ដែលទាមទារឱ្យមានការដោះស្រាយជាយុទ្ធសាស្ត្រ

- ❖ បញ្ហាប្រឈមផ្នែកហិរញ្ញវត្ថុ និងនីតិវិធីថវិកា
- ❖ ការអនុវត្តគម្រោងមូលនិធិឃុំ សង្កាត់ខុសគោលដៅនិងខុសនីតិវិធី
- ❖ បន្ទុកការងារ និងកង្វះខាតធនធានមនុស្ស
- ❖ ភាពមិនទាន់ស៊ីសង្វាក់គ្នានៃការសមាហរណកម្មគម្រោង
- ❖ គុណភាព និងភាពត្រឹមត្រូវនៃការផ្តល់សេវា
- ❖ គម្លាតសមត្ថភាពក្នុងការធ្វើបរិវត្តកម្មឌីជីថល
- ❖ វិសមភាពនៃការអភិវឌ្ឍរវាងមូលដ្ឋាន

# V-ទិសដៅយុទ្ធសាស្ត្រ សម្រាប់អាណត្តិទី៦

## ១-ចក្ខុវិស័យ និងគោលការណ៍គ្រឹះ




ក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវបំពេញតួនាទី

- ❖ ជាស្ថាប័នតំណាងប្រជាពលរដ្ឋ
- ❖ ជាស្ថាប័នធ្វើសេចក្តីសម្រេច
- ❖ ជាអ្នកដឹកនាំការអភិវឌ្ឍមូលដ្ឋាន
- ❖ ជាអ្នកសម្របសម្រួលសេវា និង
- ❖ ជាស្ពានតភ្ជាប់រវាងប្រជាពលរដ្ឋ ជាមួយរាជរដ្ឋាភិបាល ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិគ្រប់លំដាប់ថ្នាក់។

# V-ទិសដៅយុទ្ធសាស្ត្រ សម្រាប់អាណត្តិទី៦

## ១-ចក្ខុវិស័យ និងគោលការណ៍គ្រឹះ

**គោលការណ៍ទាំង៧ចំណុច**

១ ប្រជាពលរដ្ឋជាមជ្ឈមណ្ឌលនៃការគ្រប់គ្រង និងការផ្តល់សេវា

២ ការផ្ទេរមុខងារត្រូវភ្ជាប់ជាមួយធនធាន បុគ្គលិក សិទ្ធិសម្រេច និងខ្សែគណនេយ្យភាពច្បាស់លាស់

៣ ការរៀបចំផែនការ និងថវិកាត្រូវផ្អែកលើទិន្នន័យច្បាស់លាស់ និងតម្រូវការអាទិភាពជាក់ស្តែង

៤ ការអភិវឌ្ឍត្រូវមានបរិយាបន្ន សមធម៌ និងឈរលើគោលការណ៍ «មិនបោះបង់នរណាម្នាក់ចោល»

៥ ការអនុវត្តគម្រោងត្រូវប្រកាន់ខ្ជាប់នូវតម្លាភាព គុណភាព តម្លៃសម្រាប់ថវិកា និងចីរភាព

៦ ការងារឌីជីថលត្រូវក្លាយជាឧបករណ៍ពង្រឹងប្រសិទ្ធភាព និងសម្រួលកិច្ចការ មិនជាបន្ទុកដល់មន្ត្រី

៧ ការតាមដាន វាយតម្លៃត្រូវផ្អែកលើផលសម្រេច និងផលប៉ះពាល់ជាក់ស្តែង ចំពោះជីវភាពរបស់ប្រជាពលរដ្ឋ

# V-ទិសដៅយុទ្ធសាស្ត្រ សម្រាប់អាណត្តិទី៦

## ២-វិធានការអនុវត្តគន្លឹះសំខាន់។

**វិធានការអនុវត្តគន្លឹះសំខាន់។**

1. ការលើកកម្ពស់គុណភាពសេវាសាធារណៈ និងសេវារដ្ឋបាលដោយយកប្រជាពលរដ្ឋជាមជ្ឈមណ្ឌល
2. ការពង្រឹងការផ្ទេរមុខងារនិងការគ្រប់គ្រងធនធានមនុស្ស
3. ការកែលម្អការគ្រប់គ្រងថវិកា និងការពន្លឿនការផ្ទេរធនធាន
4. ការពង្រឹងប្រសិទ្ធភាពផែនការ ការវិនិយោគ និងការសមាហរណកម្មគម្រោង
5. ការជំរុញបរិវត្តកម្មឌីជីថល និងទំនើបកម្មប្រព័ន្ធការងារ
6. ការពង្រឹងការគាំពារសង្គម សមភាពយេនឌ័រ និងការគ្រប់គ្រងបរិស្ថាន
7. ការកែលម្អប្រព័ន្ធតាមដាន វាយតម្លៃ ផ្អែកលើផលសម្រេច។

# VI-សេចក្តីសន្និដ្ឋានរួម

១ ភាពរឹងមាំនៃលទ្ធិប្រជាធិបតេយ្យនៅមូលដ្ឋាន

២ ការផ្លាស់ប្តូរជាយុទ្ធសាស្ត្រនៃរដ្ឋបាលមូលដ្ឋាន

៣ ការបម្លែងគោលនយោបាយជាតិទៅជាសកម្មភាពជាក់ស្តែង

# សូមអរគុណ!